អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន
# ព្រះមេធានុរក្ស វជិរប្បញ្ញោ បណ្ឌិត គូ សុភាព ព្រះធម្មធរគណរាជធានីភ្នំពេញ នឹងនិមន្តចូលរួមជាវាគ្មិនកិត្តយសក្នុងកិច្ចពិភាក្សា
# អំពី
# “យុត្តិធម៌អន្តរកាល៖ ការស្វែងយល់អំពីឥទ្ធិពលនៃគោលជំនឿក្នុងការផ្សះផ្សា និងការចងចាំ”

ព្រះមេធានុរក្ស វជិរប្បញ្ញោ បណ្ឌិត គូ សុភាព ព្រះធម្មធរគណរាជធានីភ្នំពេញ នឹងនិមន្តចូលរួមជាវាគ្មិនកិត្តយសក្នុងកិច្ចពិភាក្សាស្តីអំពី “យុត្តិធម៌អន្តរកាល៖ ការស្វែងយល់អំពីឥទ្ធិពលនៃជំនឿក្នុងការផ្សះផ្សានិងការចងចាំ” នៅថ្ងៃសុក្រ ទី១៦ ខែសីហា ឆ្នាំ២០២៤ ចាប់ពីម៉ោង១០:៣០នាទីព្រឹក ដល់ម៉ោង១២:០០នាទីថ្ងៃត្រង់ នៅក្នុងសាលពហុបំណង(ជាន់ទី២) នៃមជ្ឈមណ្ឌលធនធានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក.) អគារលេខ៤០ មហាវិថីសហព័ន្ធរុស្សី សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។ កិច្ចពិភាក្សានេះត្រូវបានសហការរៀបចំឡើងដោយអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា (អ.វ.ត.ក) និងក្នុងកម្មវិធីភាពជាដៃគូសម្រាប់ការកសាងសន្តិភាពសាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ (SAUP) នៃអង្គការGIZ សម្រាប់សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងគ្រូបង្រៀន ប្រមាណ៥០រូប មកពីសាកលវិទ្យាល័យនៅព្រះរាជាណាចក្រកម្ពុជា ហ្វីលីពីន អាឡឺម៉ង់ និងទីម័រលេស្តេ។ នៅក្នុងកិច្ចពិភាក្សានេះ ព្រះមេធានុរក្ស វជិរប្បញ្ញោ បណ្ឌិត គូ សុភាព នឹងមានសង្ឃដីកាអំពី “យុត្តិធម៌អន្តរកាល” នៅក្នុងជំនឿសាសនាព្រះពុទ្ធ។ កិច្ចពិភាក្សានេះ នឹងមានវាគ្មិនពីសាសនាឥស្លាម និងសាសនាគ្រិស្ត ចូលរួមបកស្រាយ~~អំពី “យុត្តិធម៌អន្តរកាល” នៅក្នុងគោលជំនឿសាសនានាឥស្លាម និងសាសនាគ្រិស្ត~~ផងដែរ។

*សេចក្តីណែនាំសម្រាប់សារព័ត៌មាន*

សម្រាប់តំណាងសារព័ត៌មានទាំងឡាយដែលមានបំណងអញ្ជើញមករាយការណ៍ព័ត៌មានដោយផ្ទាល់ពីកម្មវិធីនេះ សូមទាក់ទងចុះឈ្មោះតាមរយៈលេខទូរស័ព្ទ ឬតេលេក្រាម៖

**លោក យ៉ា វសាត់** ០៦៦ ២៥៩ ៨៩៨

**លោកស្រី ស៊ុយ ធីតា** ០១២ ៨៥៥ ៤០៥

**កំណត់ចំណាំចំពោះបណ្ណាធិការព័ត៌មាន**

**សមិទ្ធផលរបស់ អ.វ.ត.ក. ពីខែមករា ឆ្នាំ២០២៣ ដល់ខែមិថុនា ឆ្នាំ២០២៤**

ផ្អែកតាមស្មារតី«**កិច្ចព្រមព្រៀងបន្ថែមស្ដីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ**» នៅឆ្នាំ២០២១ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ អ.វ.ត.ក. ត្រូវបានផ្ដល់អាណត្តិឱ្យអនុវត្តមុខងារសេសសល់ដែលរួមមានមុខងារគតិយុត្តិ និងមិនមែន គតិយុត្តិ សម្រាប់រយៈពេល៣ឆ្នាំដំបូងពីឆ្នាំ២០២៣ ដល់២០២៥។ ចាប់ពីដើមឆ្នាំ២០២៣កន្លងមកនេះ ភាគីជាតិនិងភាគីអន្តរជាតិនៃអ.វ.ត.ក. បានចាប់ផ្ដើមអនុវត្តមុខងារសេសសល់របស់ខ្លួននៅឆ្នាំទី១ និងសម្រេចបាននូវសមិទ្ធផលការងារសំខាន់ៗជាច្រើន រួមមាន៖

- បានផ្ទេរពិរុទ្ធជន ខៀវ សំផន ដែលមានអាយុ៩៤ឆ្នាំ ទៅអនុវត្តទោសអស់មួយជីវិតនៅពន្ធនាគារខេត្តកណ្ដាលកាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយក-ដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ។ បច្ចុប្បន្ន អ.វ.ត.ក. បាននិងកំពុងតាមដានការអនុវត្តទោសចំពោះពិរុទ្ធជននេះជាមួយគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម (ICRC) ដោយផ្អែកលើបទដ្ឋាននិងទម្លាប់អនុវត្តជាអន្តរជាតិ ព្រមទាំងស្មារតីនៃកិច្ចព្រមព្រៀងបន្ថែមខាងលើ។
- ទី២-បានបំពេញកាតព្វកិច្ចដូចបានតម្រូវឱ្យអនុវត្តនៅក្នុងសាលដីកាស្ថាពរ នៃសំណុំរឿង ០០២/០២ ក្នុង ការជូនដំណឹងអំពីបច្ចុប្បន្នភាពនៃសមិទ្ធផលការងារសម្រេចបាននិងការអនុវត្តមុខងារសេសសល់របស់ អ.វ.ត.ក. ដល់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រមាណ ៣ ១០០ នាក់ ស្មើនឹង៨០% នៃដើមបណ្ដឹងរដ្ឋប្បវេណីសរុបចំនួន ៣ ៨៧៥នាក់ ដែលបាននិងកំពុងរស់នៅក្នុង២៥ រាជធានី ខេត្ត។
- បានធ្វើចំណាត់ថ្នាក់ពីប្រភេទឯកសារសម្ងាត់បំផុតនិងសម្ងាត់ ទៅជាឯកសារសាធារណៈនៃឯកសារសំណុំរឿង០០២ បានចំនួនប្រមាណ២២ម៉ឺនទំព័រ និងកំពុងពិនិត្យមើលឯកសារសំណុំរឿងដ៏ទៃទៀត ប្រមាណជា២លានទំព័រ សម្រាប់ធ្វើការផ្សព្វផ្សាយជាសាធារណៈ។
- ទី៤-បានរៀបចំនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ «មជ្ឈមណ្ឌលធនធានរបស់អ.វ.ត.ក.» កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ។ មជ្ឈមណ្ឌលធនធាននេះរួមមានសមាសភាគចំនួនប្រាំមួយ ក្នុងនោះសមាសភាគចំនួនបួនត្រូវបានកសាងរួចរាល់និងកំពុងដាក់ឱ្យដំណើរការរួចហើយ រួមមាន៖

  (ទី១). បណ្ណាល័យនិងកន្លែងស្រាវជ្រាវ

  (ទី២). និហិតដ្ឋានបណ្ណសារ (Archives Repository)

  (ទី៣). បន្ទប់ប្រើប្រាស់ពហុបំណងសម្រាប់រៀបចំសិក្ខាសាលានិងតុលាការត្រាប់

  (ទី៤). គេហទំព័រថ្មីមានលក្ខណៈអន្តរកម្ម (interactive features) របស់អ.វ.ត.ក.។

ហើយមានគម្រោងការងារចំនួនពីរទៀត រួមមាន (ទី១). ការសាងសង់បន្ទប់ពិគ្រោះយោបល់សម្រាប់ជនរងគ្រោះ និងសាលតាំងពិព័រណ៍អចិន្ត្រៃយ៍ស្ដីពីដំណើរការជំនុំជម្រះក្ដី, និង(ទី២). ឧទ្យានសម្រាប់ការចងចាំ គ្រោងនឹងសាងសង់បញ្ចប់នៅឆ្នាំ២០២៤ និងឆ្នាំ២០២៥។

ទី៥-បាននិងកំពុងរៀបចំដំណើរទស្សនកិច្ចសិក្សា២លើកក្នុងមួយសប្ដាហ៍ដល់សាធារណជន ជាពិសេស យុវជនយុវនារី សិស្សនិស្សិត និងគ្រូបង្រៀនដែលមានអ្នកចូលរួមសរុបប្រមាណ ៤០ ២៩៣ នាក់ ចាប់ពីខែមករា ឆ្នាំ២០២៣រហូតមកទល់ខែមិថុនា ឆ្នាំ២០២៤។ អ្នកចូលរួមកម្មវិធីនេះ ត្រូវបានពន្យល់អំពីដំណើរការ និងសមិទ្ធផលសម្រេចបានរបស់អ.វ.ត.ក., ទៅទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង, សារមន្ទីរវាលពិឃាតជើងឯក, និងវិមានឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល។

ទី៦-បានផលិតវីដេអូខ្លីៗទៅលើប្រធានបទជាច្រើន ទាក់ទងទៅនឹងអាណត្តិនិងការងារប្រតិបត្តិការរបស់អ.វ.ត.ក. និងជាពិសេសសបានផលិត «កម្មវិធីវីដេអូខ្លីអប់រំនិងផ្សព្វផ្សាយជាស៊េរី» ចំនួនសរុប ៤២ភាគដែលមានទម្រង់ជាលក្ខណៈសំណួរនិងចម្លើយទាក់ទងនឹងការបង្កើតនិងដំណើរការកាត់សេចក្ដីនៃគ្រប់សំណុំរឿងចំនួន៧ទាំងអស់អ.វ.ត.ក.។ កម្មវិធីនេះ មានគោលបំណងពង្រីកការយល់ដឹងជាលក្ខណៈសម្រាយឬស្រួលយល់ដល់យុវជនកម្ពុជា ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរនិងអំពើសាហាវយង់ឃ្នងនៃរបបខ្មែរក្រហម តាមរយៈប្រព័ន្ធផ្សព្វផ្សាយប្រជាប្រិយរបស់យុវជន ដូចជា Facebook, Telegram, YouTube, TikTok, Instagram, និងតាមប្រព័ន្ធទូរទស្សន៍ផងដែរ។

ទី៧-បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU)ចំនួន៨ ជាមួយដៃគូជាស្ថាប័នជាតិនិងអន្តរជាតិក្នុងការចែករំលែកនិងផ្លាស់ប្ដូរចំណេះដឹង, ចំណេះធ្វើ, បទពិសោធ, និងយុត្តិសាស្ត្រ (Jurisprudences) របស់អ.វ.ត.ក. ទាក់ទងនឹងយុត្តិធម៌អន្តរកាល (Transitional Justices) ដែលជាយុត្តិធម៌ក្រោយដំណោះស្រាយជម្លោះប្រដាប់អាវុធ និងដំណើរការកាត់សេចក្ដី៕

អគារលេខ៤០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ២៣ ៨៦១ ៥៥៥
Building 40, Russian Federation Blvd. (110), Sangkat Mittapheap, Khan 7 Makara, Phnom Penh, Cambodia. P.O. BOX 71
Bâtiment 40, Fédération de Russie Blvd. (110), Sangkat Mittapheap, Khan 7 Makara, Phnom Penh, Cambodia. P.O. BOX 71
TEL: +855 (0) 23 861 500 | Fax: +855 (0) 23 861 555 | www.eccc.gov.kh